# ការទទួលបានកម្មសិទ្ធិដីសមូហភាពជនជាតិដើមភាគតិចនៅកម្ពុជា

## សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា

សហគមន៍ជនជាតិដើមភាគតិចមានប្រមាណជា **៤០០ ០០០** នៅកម្ពុជា ដែលស្មើនឹង **២ ទៅ ៣%** នៃពលរដ្ឋសរុប។

សហគមន៍ជនជាតិដើមភាគតិចបែងចែកជា **៤៥៨** សហគមន៍ ដែលតំណាងឱ្យជនជាតិដើមភាគតិច **២៤** ផ្សេងគ្នាដោយមានភាសាចំនួន **២៣** ស្ថិតនៅទូទាំងខេត្តចំនួន **១៥** ក្នុងប្រទេស។ សហគមន៍ជនជាតិដើមភាគតិចបានរស់នៅក្នុងទឹកដីប្រទេសកម្ពុជារាប់ពាន់ឆ្នាំមកហើយ ដោយបានចាក់ស្រេះនូវវប្បធម៌នៅលើដីដែលខ្លួនកំពុងរស់នៅ។



## ប័ណ្ណកម្មសិទ្ធិដីសមូហភាព

**ប័ណ្ណកម្មសិទ្ធិដីសមូហភាព** គឺជា**កម្មសិទ្ធិរួម** និងសិទ្ធិរបស់សហគមន៍ចំពោះដីធ្លី និងធនធានធម្មជាតិ។

ប័ណ្ណកម្មសិទ្ធិដីសមូហភាព បានផ្តល់នូវការការពារស្របច្បាប់ចំពោះដីសហគមន៍ របស់សហគមន៍ជនជាតិដើមភាគតិច ដោយផ្តល់នូវប្រាក់ចំណូល និងសន្តិសុខស្បៀង ព្រមទាំងការពារពីការរំលោភយកដីទាំងស្របច្បាប់ និងខុសច្បាប់ផងដែរ។ មិនត្រឹមតែប៉ុណ្ណោះ ប័ណ្ណកម្មសិទ្ធិដីសមូហភាពក៏រួមចំណែកដល់ការអភិរក្សនូវអត្តសញ្ញាណ និងវប្បធម៌ ព្រមទាំងជួយការពារដល់សិទ្ធិក្នុងការសម្រេចចិត្តដោយខ្លួនឯងនៃសហគមន៍ជនជាតិភាគតិចផងដែរ។

នៅកម្ពុជាប័ណ្ណកម្មសិទ្ធិដីសមូហភាព សម្រាប់ជនជាតិដើមភាគតិចលើដីប្រពៃណីរបស់ខ្លួន ត្រូវបានទទួលស្គាល់ដោយ**ច្បាប់ភូមិបាលឆ្នាំ២០០១** និងកំណត់ដោយ**អនុក្រឹត្រលេខ.៨៣ ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច**។

ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែងការចុះបញ្ជីដីសមូហភាព នៅតែបន្តមាន**ចំនួនតិចតួចបំផុត**។

## ប័ណ្ណកម្មសិទ្ធិដីសមូហភាពដែលបានផ្តល់ជូនសហគមន៍ជនជាតិដើមភាគតិច

តាមការសង្កេតមើលរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) ចាប់ពីឆ្នាំ២០១១ រហូតដល់ខែសីហា ឆ្នាំ២០២១ មាន**ប័ណ្ណកម្មសិទ្ធិដីសមូហភាពចំនួន ៣៣** បានផ្តល់ជូនសហគមន៍ជនជាតិដើមភាគតិចចំនួន **៣៣** ដែលស្មើរនឹង **៧,២%** ប៉ុណ្ណោះនៃសហគមន៍ជនជាតិដើមភាគតិចសរុបនៅកម្ពុជា។ ប័ណ្ណកម្មសិទ្ធិដីសមូហភាពចំនួន ៣៣ នេះគ្របដណ្តប់លើដីសហគមន៍ចំនួន ៣៣.៨៩៩ ហិចតា ដែលមានជនជាតិដើមភាគតិចចំនួន ៣.២៣៥ គ្រួសារកំពុងរស់នៅ។




បច្ចុប្បន្នមានសហគមន៍ជនជាតិដើមភាគតិចផ្សេងៗគ្នាកំពុងដំណើរការស្នើសុំចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីសមូហភាព ខណៈដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មិនបានផ្តល់នូវប័ណ្ណកម្មសិទ្ធិដីសមូហភាពថ្មីណាមួយ ដល់សហគមន៍ជនជាតិដើមភាគតិចឡើយ ចាប់តាំងពីខែធ្នូ ឆ្នាំ២០២០ មក បើទោះបីជាមានការប្តេជ្ញាចិត្តក្នុងឆ្នាំ២០១៧ ដើម្បីពន្លឿនការចុះបញ្ជីដីធ្លីជូនជនជាតិដើមភាគតិច និងផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចយ៉ាងហោច**ចំនួន១០ សហគមន៍ក្នុងមួយឆ្នាំក៏ដោយ**។

## ឧបសគ្គក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនៅកម្ពុជា

សហគមន៍ជនជាតិដើមភាគតិចប្រឈមនឹងឧបសគ្គផ្សេងៗ ក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពដែលជាហេតុនៃការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីសមូហភាពមានចំនួនទាប។ ឧបសគ្គចម្បងរួមមាន៖

- ការអនុវត្តច្បាប់ដែលការពារសិទ្ធិដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិចមិនបានល្អ
- ដំណើរការស្មុគស្មាញ មានរយៈពេលវែង និងថ្លៃ
- ខ្វះខាតធនធានក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិច
- កង្វះខាតការយល់ដឹងនៃដំណើរការចុះបញ្ជីទាំងអាជ្ញាធរ និងសហគមន៍ជនជាតិដើមភាគតិច
- កង្វះខាតការយល់ដឹងទៅលើសិទ្ធិដីធ្លីក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិច
- ការកើនឡើងនៃការឆ្លងជំងឺកូវីដ១៩ នៅក្នុងកម្ពុជាដែលធ្វើឱ្យរដ្ឋាភិបាលបន្ថយនូវសកម្មភាពការងាររបស់ខ្លួនដោយរួមទាំងការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីសមូហភាព
- ការបិទខ្ទប់ និងការបិទព្រំប្រទល់ ដោយសារតែជំងឺកូវីដ១៩ បានបង្អាក់នូវការផ្តើមគំនិតរបស់សហគមន៍ជនជាតិដើមភាគតិចពីដំណើរការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីសមូហភាព។

## អនុសាសន៍

**ម.ស.ម.ក សូមលើកទឹកចិត្តដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការចាត់វិធានការបន្ថែមទៀតដើម្បីពន្លឿនការចុះបញ្ជី និងដោះស្រាយឧបសគ្គនានារបស់សហគមន៍ជនជាតិដើមភាគតិចដែលមានបំណងចង់ចុះបញ្ជីដីសហគមន៍របស់ខ្លួន។**

ប្រភព៖
១. របាយការណ៍មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា “ការចុះបញ្ជីដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា” ២០១៦។
២. របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងាររបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights
@CCHRCambodia
@CCHRCambodia
cchrcambodia.org
sithi.org

ខែសីហា ឆ្នាំ២០២១

CC BY NC SA